# ចូរបំពេញព័ត៌មានឡើងវិញ
# ដើម្បីបន្ត MEDI-CAL របស់អ្នក




*ការបញ្ជាក់ឡើងវិញប្រចាំឆ្នាំ ដើមបន្តការធានារ៉ាប់រងសុខភាព*

*ខែមេសា ឆ្នាំ 2023*

## បំពេញព័ត៌មានប្រចាំឆ្នាំរបស់អ្នកឡើងវិញ ដើម្បីបន្តការធានារ៉ាប់រង MEDI-CAL របស់អ្នក

## មានវិធី 3 យ៉ាង ដើម្បីបំពេញព័ត៌មានឡើងវិញប្រចាំឆ្នាំ

### តាមអនឡាញ

សូមចូលទៅគណនីអត្ថប្រយោជន៍របស់អ្នក ហើយបំពេញព័ត៌មានតាមអ៊ីនធឺណិតសម្រាប់ការសុំបន្ត និងត្រូវបង្ហាញភស្តុតាងអំពីប្រាក់ចំណូលរបស់អ្នក (ចុងសន្លឹកបង្កាន់ដៃបង់ប្រាក់ថ្មីៗ ឬទម្រង់ឯកសារបង់ពន្ធ) ផងដែរ!

ពុំមានគណនីដើម្បីបំពេញព័ត៌មាន? សូមចូលទៅកាន់ www.benefitscal.com ហើយបង្កើតគណនីមួយ។ អ្វីដែលអ្នកត្រូវការគឺ លេខទូរស័ព្ទដៃ ឬ អាសយដ្ឋានអ៊ីមែល។

### តាមប្រៃសណីយ៍

ប្រសិនបើអាសយដ្ឋានប្រៃសណីយ៍របស់អ្នកនៅដំណើរការ អ្នកនឹងទទួលបានកញ្ចប់សម្រាប់បញ្ជាក់ព័ត៌មានឡើងវិញ បីខែមុនដល់ពេលកំណត់។ សូមបំពេញព័ត៌មាន និងផ្ញើកញ្ចប់នេះមកវិញ តាមកាលបរិច្ឆេទកំណត់ សូមប្រាកដថា មានភ្ជាប់ ភស្តុតាងអំពីប្រាក់ចំណូលរបស់អ្នក (ចុងសន្លឹកបង្កាន់ដៃបង់ប្រាក់ថ្មីៗ ឬ ទម្រង់ឯកសារបង់ពន្ធ) ផងដែរ!

### តាមទូរស័ព្ទ៖

សូមទូរស័ព្ទតាមប្រព័ន្ធសេវាបន្ទាន់សម្រាប់អតិថិជន DPSS ខោនធី LA តាមលេខ 866-613-3777 ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ចាប់ពីម៉ោង 7:30 ព្រឹក ដល់ 6:30 ល្ងាច។

**តើអ្នកត្រូវការឱ្យជួយក្នុងការបង្ហាញ ឬបំពេញកញ្ចប់ព័ត៌មានឡើងវិញឡើងវិញ?**

ក្រសួងសុខភាពរបស់អ្នកប្រចាំក្រុងឡុងប៊ិចអាចជួយបាន។ យើងអាចជួយផ្ទាល់ ដើម្បីផ្តល់ការណែនាំជាភាសា អង់គ្លេស អេស្ប៉ាញ និងខ្មែរ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក ដល់ 5:00 ល្ងាច។

ទីតាំង៖ 2525 Grand Avenue
ឡុងប៊ិច CA 90815
ទូរស័ព្ទ៖ 562-570-7979, អ៊ីមែល៖ coveredlb@longbeach.gov

DHCS BenefitsCal COVERED CALIFORNIA LONGBEACH HEALTH & HUMAN SERVICES